# ដំណឹងល្អ និងព្រះគម្ពីរ៖ របៀបអានព្រះគម្ពីរ

ម៉ៃខ ប៊ូលម័រ Mike Bullmore

កូនសៀវភៅដៃគូក្នុងដំណឹងល្អ

http://www.dkdl.org

**The Gospel and Scripture**
**Copyright © 2012 by The Gospel Coalition**

**Published by Crossway**
**a publishing ministry of Good News Publishers**
**Wheaton, Illinois 60187, U.S.A.**

**This edition published by arrangement with Crossway.**
**All rights reserved.**

**This project was accomplished in partnership with The Gospel Coalition International Outreach.**

# មាតិកា


ដំណឹងល្អ គឺជាបុព្វហេតុ និងជាលទ្ធផលនៃការបើកសំដែងនៅក្នុងព្រះគម្ពីរ ៥

សេចក្តីជំនឿមុតមាំគ្រឹះចាំបាច់សំរាប់ការអានបទគម្ពីរត្រឹមត្រូវ ១១

យើងត្រូវតែមានការបន្ទាបខ្លួននៅក្នុងចិត្ត ១៧

វិធីសាស្រ្តកាត់ស្រាយមួយដែលយើងត្រូវការជាចាំបាច់ ២០

សំរាប់ករអានបន្ថែម ៣៤

គ្រីស្ទបរិស័ទយល់ស្របថា មានទំនាក់ទំនង សំខាន់ និងស៊ីជំរៅរវាងព្រះគម្ពីរ និងដំណឹងល្អ អំពីព្រះយេស៊ូវគ្រីស្ទ។ លក្ខណៈពិតនៃទំនាក់ទំនង នេះគឺជារឿងមួយដែល តម្រូវឲ្យយើងធ្វើការពិចារណាឲ្យបានជ្រាលជ្រៅ។ របៀបផ្សេងៗជាច្រើនដែលជួយយើងឲ្យមើលឃើញនូវទំនាក់ទំនងរវាងព្រះគម្ពីរនិងដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទត្រូវបានគេលើកយកមកធ្វើការសិក្សាស្រាវជ្រាវ។ ជំពូកនេះពន្យល់អំពីទំនាក់ទំនង ដ៏ជាក់លាក់ពីរយ៉ាងរវាងព្រះគម្ពីរ និងដំណឹងល្អ។

១. ដំណឹងល្អគឺជាបុព្វហេតុដែលធ្វើឲ្យការបើកសំដែង ត្រូវបានសរសេរឡើងនៅក្នុងព្រះគម្ពីរ ហើយ

២. ដំណឹងល្អគឺជាលទ្ធផលនៃការបើកសំដែងដែលត្រូវបានសរសេរឡើងនៅក្នុងព្រះគម្ពីរ

ឬអាចនិយាយបានម៉្យាងទៀតថាព្រះរាជបំណងនៃការប្រោសលោះ (ព្រះរាជសារនៃដំណឹងល្អ) ដ៏មហិមា និងអស់កល្បជានិច្ចរបស់ព្រះ គឺជា

ហេតុផលចំបងដែលនាំឲ្យមានការសរសេរនូវព្រះគម្ពីរឡើង ហើយគោលបំណងដែលព្រះគម្ពីរត្រូវបានសរសេរឡើង គឺដើម្បីសំរេចនូវព្រះរាជបំណងរបស់ព្រះ នៅក្នុងដំណឹងល្អ។

## ដំណឹងល្អ គឺជាបុព្វហេតុ និងជាលទ្ធផលនៃការបើកសំដែងនៅក្នុងព្រះគម្ពីរ

*បុព្វហេតុ*

និយាយឲ្យបានទូលំទូលាយទៅ បើសិនជាយើងគិតថាដំណឹងល្អគឺជាព្រះរាជបំណងដ៏ល្អនិងអស់កល្បជានិច្ចរបស់ព្រះ ក្នុងការប្រោសលោះមនុស្សមួយចំនួនទុកជារាស្ត្ររបស់ទ្រង់ (១ពេត្រុស ២:៩) ហើយស្តារឡើងវិញនូវស្នាព្រះហស្តរបស់ព្រះដែលបានធ្លាក់ចុះទៅក្នុងអំពើបាប (រ៉ូម ៨:១៩-២១) នោះមានន័យថា«ដំណឹងល្អ» នេះ មានមុនសំណេរនៃការបើកសំដែងក្នុងព្រះគម្ពីរ ហើយដំណឹងល្អនេះគឺជាបុព្វហេតុដែលនាំឲ្យមាននូវសំណេរនៃការបើកសំដែងក្នុងព្រះគម្ពីរ ។ គ្រប់ទាំងបទគម្ពីរត្រូវបានសរសេរឡើងតាមបំណងព្រះហឫទ័យរបស់ព្រះ។ ក្នុងន័យនេះ ដំណឹងល្អគឺជាបុព្វហេតុនៃការបើកសំដែងក្នុងព្រះគម្ពីរ។ ព្រះគម្ពីរផ្ទាល់មិនមែនជាដំណឹងល្អទេ ប៉ុន្តែសេចក្តីទាំងអស់នៅក្នុងព្រះគម្ពីរ មានទំនាក់ទំនងនឹងដំណឹងល្អ ហើយដំណឹងល្អគឺជាហេតុផលនៃការសរសេរនូវព្រះគម្ពីរឡើង។ ដំណឹងល្អគឺជាព្រះរាជសារដ៏សំខាន់ និងរួមនៃព្រះគម្ពីរ។

ព្រះរាជបំណងរបស់ព្រះនៅក្នុងការបើកសំដែងមិនអាចកាត់ផ្តាច់

ចេញពីព្រះរាជបំណងរបស់ទ្រង់នៅក្នុងការប្រោសលោះនោះទេ។ តាំងពីអស់កល្បជានិច្ចមក ព្រះ មានគម្រោងប្រោសលោះមនុស្សមួយចំនួនទុកជារាស្ត្ររបស់ទ្រង់។

> សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ តាមដែលទ្រង់បានរើស យើងរាល់គ្នាក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកិយមក ប្រយោជន៍ឱ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្ដីស្រឡាញ់ ពីព្រោះទ្រង់បានដំរូវយើងរាល់គ្នាទុកជាមុន សំរាប់ឱ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះគ្រីស្ទតាមបំណងព្រះហឬទ័យទ្រង់ ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់ ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ (អេភេសូរ ១:៣-៦)[១]

ផែនការរបស់ព្រះគឺជាមូលដ្ឋានគ្រឹះនៃការប្រាស្រ័យទាក់ទងរបស់ព្រះជាមួយមនុស្ស តាមរយៈព្រះបន្ទូល ហើយជាបុព្វហេតុដែលធ្វើឲ្យមានការប្រាស្រ័យទាក់ទងតាមរយៈព្រះបន្ទូល កើតឡើង។ ការប្រាស្រ័យទាក់ទងរបស់ព្រះតាមរយៈព្រះបន្ទូលត្រូវបានរក្សាទុកនៅក្នុងព្រះគម្ពីរ។

ការបើកសំដែងមានបង្កប់នូវគោលបំណង។ ព្រះសព្វព្រះទ័យសំរេចនូវព្រះរាជកិច្ចរបស់ទ្រង់ តាមរយៈការបើកសំដែងអំពីអង្គទ្រង់:

> ពីព្រោះដែលភ្លៀងនឹងហិមៈធ្លាក់ចុះមកពីលើមេឃឥតវិលត្រ
> ឡប់ទៅលើវិញ គឺមកស្រោចដីធ្វើឱ្យកើតចេញជាពន្លកឡើង
> ហើយក៏ឱ្យពូជពង្រោះដល់អ្នកដែលព្រោះ នឹងអាហារដល់អ្នកដែល
> បរិភោគជាយ៉ាងណា នោះពាក្យអញ ដែលចេញពីមាត់អញទៅ
> ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាង
> ដូច្នោះដែរ គឺនឹងធ្វើសំរេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុងចិត្តអញ
> ហើយនឹងចំរើនីកើនឡើង ក្នុងការអ្វី ដែលអញចាត់ទៅធ្វើនោះ
> (អេសាយ ៥៥:១០-១១)

ព្រះបញ្ជូនព្រះបន្ទូលរបស់ទ្រង់មកដើម្បីសំរេចនូវព្រះរាជបំណងដ៏អស់កល្បជានិច្ច របស់ទ្រង់ក្នុងការប្រោសលោះមនុស្សមួយចំនួនទុកជារាស្ត្ររបស់ទ្រង់ ហើយព្រះមានបន្ទូលតាមរយៈហោរាអេសាយអំពីការប្រមូលមនុស្សសំរាប់ទ្រង់ថាៈ

> ចូរឱនត្រចៀក ហើយមកឯអញ ចូរស្តាប់ចុះ នោះព្រលឹងឯង
> នឹងបានរស់នៅ ហើយអញនឹងតាំងសេចក្តីសញ្ញានឹងឯងរាល់គ្នា
> ជាសញ្ញាដ៏នៅអស់កល្បជានិច្ច គឺជាសេចក្តីមេត្តាករុណាស្មោះត្រង់
> ដែលបានផ្តល់ដល់ដាវីឌ មើល អញបានតាំងដាវីឌទុកជាទីបន្ទាល់
> ដល់ប្រជាជាតិទាំងឡាយ គឺជាអ្នកនាំមុខ ហើយជាអ្នក
> បង្គាប់ដល់គេ មើល ឯងនឹងហៅសាសន៍១ ដែលឯងមិនបានស្គាល់
> ហើយសាសន៍១ ដែលមិនបានស្គាល់ឯងគេនឹងរត់មកឯឯង
> ដោយព្រោះព្រះយេហូវ៉ាជាព្រះនៃឯងគឺជាព្រះដ៏បរិសុទ្ធនៃសាសន៍

អីស្រាអែល ដ្បិតទ្រង់បានលើកដំកើងឯងហើយ។ (អេសាយ ៥៥:៣-៥)

ជារឿយៗព្រះគម្ពីរសញ្ញាថ្មីពន្យល់អំពីគោលបំណងនៃការបើកសំដែងនេះយ៉ាងច្បាស់លាស់។ លោកសាវ័កប៉ុលសរសេរអំពីព្រះគម្ពីរសញ្ញាចាស់ថា "ត្បិតអស់ទាំងសេចក្ដីដែលបានចែងទុកមកជាមុន នោះបានចែងសំរាប់នឹងបង្រៀនយើងរាល់គ្នា ដើម្បីឲ្យយើងបានសេចក្ដីសង្ឃឹម ដោយសេចក្ដីអត់ធន់ និងសេចក្ដីកំសាន្តចិត្តដោយសារគម្ពីរ" (រ៉ូម ១៥:៤)។ ឲ្យមានសេចក្ដីសង្ឃឹមចំពោះអ្វី? ឲ្យមានសេចក្ដីសង្ឃឹមចំពោះសេចក្ដីប្រោសលោះដ៏ពេញលេញដែលនឹងមកជាមួយនឹងការ បំពេញសំរេចជាស្ថាពរនូវព្រះរាជបំណងដ៏ល្អរបស់ព្រះ (ប្រៀបធៀបៈ រ៉ូម ៨:១៨-២៥)។ លោក ប៉ុលនិយាយថា នេះហើយគឺជាមូលហេតុដែលព្រះបានសរសេរនូវ ព្រះគម្ពីរឡើង។ ព្រះគម្ពីរមាន ប្រយោជន៍នៅក្នុងការបើកសំដែងអំពី ព្រះរាជបំណងនិង ព្រះរាជកិច្ចនៃការប្រោសលោះរបស់ព្រះ។ ក្នុងរបៀបនេះ ដំណឹងល្អគឺជាបុព្វហេតុនៃព្រះគម្ពីរ។ ប៉ុន្តែយ៉ាងហោចណាស់ នៅក្នុងរបៀបដ៏ចាំបាច់មួយទៀត ដំណឹងល្អគឺជាលទ្ធផលនៃការបើកសំដែងក្នុងព្រះគម្ពីរ។

## *លទ្ធផល*

យើងក៏និយាយអំពីដំណឹងល្អ ដោយផ្ដោតទៅលើភាពស័ក្តិសិទ្ធិ នៃការប្រកាសរបស់វាផងដែរ។ នៅក្នុងន័យនេះ ការបើកសំដែងចាំបាច់ត្រូវ មកមុនដំណឹងល្អ ហើយដំណឹងល្អកើតឡើងយ៉ាងស័ក្តិសិទ្ធិ ពីការបើកសំដែងនៅក្នុងព្រះគម្ពីរ។

ដំណឹងល្អគឺជាព្រះរាជសារចំបងរបស់ព្រះគម្ពីរ។ ការប្រកាសនូវខ្លឹមសារនៃព្រះគម្ពីរ គឺជាការប្រកាសនូវព្រះរាជសារស្តីពីការទន្ទឹងរង់ចាំ ការសំរេចតាមព្រះរាជបំណងនៅក្នុងការប្រោសលោះរបស់ព្រះតាមរយៈព្រះគ្រីស្ទ ដូចបានចែងទុកនៅក្នុងទំនាយរបស់ពួកហោរានៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងការបំពេញសំរេចនូវព្រះរាជកិច្ចរបស់ព្រះគ្រីស្ទដូចដែលពួកសាវ័កបានធ្វើជាស្មរបន្ទាល់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ការអធិប្បាយខ្លឹមសារនៃព្រះគម្ពីរគឺជាការ ស្រាយនូវអំណាច នៃព្រះរាជសាររបស់ដំណឹងល្អ ហើយសំរេចនូវព្រះរាជបំណងរបស់ព្រះដែលមានតាំងពីដើមរៀងមក។

លោកសាវ័កប៉ុលបង្រៀន សេចក្តីនេះ យ៉ាងច្បាស់លាស់នៅក្នុងរ៉ូម ១០ ដែលបង្រៀនអំពីព្រះរាជបំណងរបស់ព្រះក្នុងការប្រោសលោះមនុស្សមួយចំនួនទុកជារាស្ត្ររបស់ទ្រង់។ លោក ប៉ុលសរសេរថាៈ

> ហើយសាសន៍យូដា និងសាសន៍ក្រិកមិនខុសអំពីគ្នាឡើយ ដ្បិតព្រះអម្ចាស់ដដែលនៃគ្រប់គ្នា ទ្រង់មានជាបរិបូរ សំរាប់អស់អ្នកណា ដែលអំពាវនាវរកទ្រង់ ហើយគ្រប់គ្នា គឺអស់អ្នកណា ដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ដូច្នេះបើគេមិនជឿ ធ្វើដូចម្តេចឱ្យគេអំពាវនាវដល់ព្រះបាន ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឱ្យ គេជឿដល់ព្រះបាន ហើយធ្វើដូចម្តេចឱ្យគេឮនិយាយបាន បើគ្មានអ្នកណាប្រាប់សោះ (រ៉ូម ១០:១២-១៤)

ពីរបីខក្រោយមកទៀត លោកសាវ័កប៉ុលសង្ខេបថា “ដូច្នេះ សេចក្តីជំនឿ

កើតឡើងដោយលឺ ហើយដែលលឺនោះ គឺដោយសារព្រះបន្ទូលនៃព្រះ» (ខ. ១៧)។ ឬអាចនិយាយបានម៉្យាងទៀតថា នៅពេលដែលយើងស្មោះត្រង់ក្នុងការប្រកាសព្រះបន្ទូលរបស់ព្រះ  ព្រះបន្ទូលរបស់ព្រះសំរេចនូវព្រះរាជបំណងដ៏ល្អរបស់ទ្រង់នៅក្នុងការប្រោសលោះ។

លោកពេត្រុសបង្រៀនអំពីសេចក្តីដូចគ្នាថា «ត្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់និងនៅជាប់លាប់....ហើយព្រះបន្ទូលនេះគឺជាដំណឹងល្អដែលបានផ្សាយមកអ្នករាល់គ្នា» (១ពេត្រុស ១:២៣-២៥)។ លោកយ៉ូហានលើកនូវ ផ្ទៃរឿងដដែល នេះមកនិយាយម្តងទៀតនៅពេលគាត់និយាយថាគាត់បានសរសេរនូវ ដំណឹងល្អរបស់គាត់។ «ដើម្បីឲ្យអ្នករាល់គ្នាបានជឿថាព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិតដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ» (យ៉ូហាន ២០:៣១)។ នេះគឺជារបៀបមួយផ្សេងទៀតក្នុងការនិយាយថា វត្តមាននៃការបើកសំដែងក្នុងព្រះគម្ពីរគឺដើម្បីបំពេញសំរេចនូវ ព្រះរាជបំណងដ៏ធំរបស់ព្រះក្នុងការប្រោសលោះមនុស្សមួយចំនួនតាមរយៈព្រះគ្រីស្ទទុកជារាស្ត្ររបស់ទ្រង់។

ដូច្នេះ ព្រះគម្ពីរមានវត្តមាន**ដោយសារ**ដំណឹងល្អហើយ**សំរាប់**ដំណឹងល្អ។ គន្លឹះសំខាន់នោះគឺថា ដំណឹងល្អគឺជាព្រះរាជសាររបស់ព្រះគ្រីស្ទ។ គ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីរចង្អុលទៅកាន់ និងពន្យល់អំពីព្រះគ្រីស្ទ។ ដូច្នេះ គ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីរមិនត្រឹមតែជួយដល់ការយល់ដឹងរបស់យើងអំពីដំណឹងល្អប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយដល់ «ការលឺ» របស់យើងអំពីដំណឹងល្អ ក្នុងគោលដៅ

ឲ្យយើងបានជឿ ហើយឲ្យព្រះបំពេញសំរេចនូវព្រះរាជបំណងដ៏ល្អរបស់ទ្រង់ក្នុងប្រោសលោះឲ្យបានយ៉ាងពេញលេញ។ ដូច្នេះ ការនេះ តម្រូវឲ្យយើងអានកាត់ស្រាយ អនុវត្ត និងបង្រៀនព្រះគម្ពីរនៅក្នុងរបៀបមួយដែល (ស្របទៅនឹង) ព្រះរាជបំណងដ៏ល្អរបស់ព្រះ។

## សេចក្ដីជំនឿមុតមាំគ្រឹះចាំបាច់សំរាប់ការអានបទគម្ពីរត្រឹមត្រូវ

មានសេចក្ដីជំនឿមុតមាំគ្រឹះមួយចំនួនដែលយើងត្រូវតែមាន និងដើរតាមដើម្បីឲ្យព្រះគម្ពីរអាចមានប្រសិទ្ធិភាពស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះ។

### *ព្រះបណ្ដាលឲ្យតែងព្រះគម្ពីរឡើង*

លោក ប៉ុលរំលឹកកូនស្ងួនភ្ងាក្នុងសេចក្ដីជំនឿរបស់គាត់ថា “គ្រប់ទាំងបទគម្ពីរគឺព្រះបណ្ដាលឲ្យតែងទេ” (២ធីម៉ូថេ ៣:១៦)។ លោក ប៉ុលកំពុងនិយាយថា បទគម្ពីរមានដើមកំណើតនៅក្នុងគំនិតរបស់ព្រះ ហើយត្រូវបាននិយាយចេញមក  (បណ្ដាល ឬបញ្ចេញមក) ពីគំនិតរបស់ព្រះ។ គ្រីស្ទបរិស័ទ ត្រូវតែមានជំនឿយ៉ាងមុតមាំថា ព្រះពិតជាបានមានបន្ទូលជាបទគម្ពីរ ដើម្បីឲ្យព្រះគម្ពីរបានកែប្រែជីវិតរបស់ពួកគេ។ នៅពេលយើងប្រើឃ្លា “ព្រះបន្ទូលនៃព្រះ” ដើម្បីសំដៅទៅលើព្រះគម្ពីររបស់យើង នោះយើងមិន ត្រូវភ្លេចខ្លឹមសារនៃឃ្លា “ព្រះបន្ទូលនៃព្រះ” នោះទេ។ ព្រះបានមានបន្ទូល។ មានការមួយជាក់លាក់ដែលទ្រង់កំពុងតែមានបន្ទូល។ ទ្រង់កំពុងតែមានបន្ទូល។ ទ្រង់កំពុងតែ

ប្រាស្រ័យទាក់ទងនឹងយើង។ ព្រះពិតជាបានមានព្រះបន្ទូល ហើយព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ទ្រង់ដែលបានសរសេរឡើងជាលាយលក្សណ៍អក្សរ។

ផលវិបាកចំបងនៃជំនឿមុតមាំនេះ គឺថា ព្រះគម្ពីរពិតនិងគួរឲ្យទុកចិត្តបាន។ «គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ» (សុភាសិត ៣០:៥)។ ការប្រកាន់ខ្ជាប់នឹងជំនឿមុតមាំនេះនឹងមានឥទ្ធពលយ៉ាងខ្លាំងទៅលើការអានព្រះគម្ពីរផ្ទាល់ខ្លួនរបស់យើង និងការឆ្លើយតបរបស់យើងចំពោះព្រះគម្ពីរ។ វានឹងធ្វើឲ្យយើងលែងសង្ស័យ និងងឿងឆ្ងល់។ បើសិនជាយើងមិនប្រកាន់ខ្ជាប់នូវជំនឿមុតមាំនេះទេ នោះយើងនឹង មានភាពស្រពិចស្រពិល មានចិត្តពីរ និងគ្មានភាពនឹងនៅពេលយើងជួបប្រទះទុក្ខលំបាកនៅក្នុងជីវិតឬនៅពេលយើងពិបាកយល់ ព្រះគម្ពីរ។

## *យើងអាចយល់បទគម្ពីរបាន*

លោកសាវ័កប៉ុលប្រាប់ធីម៉ូថេថា «ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកដូចជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការដែលមិនត្រូវខ្មាស់ឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ» (២ធីម៉ូថេ ២:១៥)។ យើងអាចកាត់ស្រាយព្រះបន្ទូលនៃព្រះបានយ៉ាងត្រឹមត្រូវ។ ឬអាចនិយាយម្យ៉ាងទៀតថា ព្រះមិនត្រឹមតែបានមានព្រះបន្ទូលទេ ប៉ុន្តែទ្រង់ក៏រំពឹងថាយើងនឹងយល់ព្រះបន្ទូលរបស់ទ្រង់ផងដែរ។ ព្រះមិនមែនជាព្រះដ៏សាហាវសព្វព្រះហឫទ័យនឹង លេងល្បែង បើកសំដែងជាមួយនិងយើងនោះទេ។ ទ្រង់មិនបានមានបន្ទូលអំពីអ្វីដែលទ្រង់ជ្រាបថាយើងនឹង

មិនយល់ ដូចជាការស្វែងរកអក្សរសម្ងាត់ដែលគ្មាននរណាអាចដោះស្រាយបាននោះឡើយ។ ទ្រង់មិនបានប្រទានព្រះរាជសារ មកក្នុងគោលដៅធ្វើឲ្យយើងម៉ូម៉ៅក្នុងចិត្តនោះទេ។ ទ្រង់មានព្រះរាជបំណង នៅពេលទ្រង់មានព្រះបន្ទូល។ មូលហេតុដែលព្រះបើកសំដែងអំពីអង្គទ្រង់ បង្ហាញថាទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សបានស្គាល់ទ្រង់។ ព្រះកំពុងសំរេចនូវគោលដៅ ដ៏ធំ ដូច្នេះទ្រង់ចង់ឲ្យយើងយល់នូវអ្វីដែលទ្រង់បានមានព្រះបន្ទូល។

ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវតែចងចាំផ្នែកដំបូងនៃ២ធីម៉ូថេ ២:១៥។ លោកសាវ័កប៉ុលប្រាប់ឲ្យធីម៉ូថេ ខិតខំប្រឹងប្រែងឲ្យអស់សមត្ថភាពរបស់គាត់ ហើយធ្វើជាអ្នកធ្វើការដែលមិនត្រូវខ្មាស់ឡើយ។ គ្មានអ្នកណាម្នាក់កើតមកចេះ ឬយល់ដោយឯងៗនោះទេ ។ ប៉ុន្តែយើងត្រូវការ ប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវជំនឿមុតមាំថា ពួកអ្នកជឿនឹងយល់នូវអត្ថន័យនៃបទគម្ពីរ ប្រសិនបើពួកគេ សិក្សាបទគម្ពីរដោយមានជំនឿមុតមាំថា នោះគឺជាព្រះបន្ទូលនៃព្រះ។ ព្រះ សព្វព្រះហឫទ័យឲ្យយើងយល់អ្វីដែលទ្រង់បានមានបន្ទូល។

## *បទគម្ពីរមានគុណប្រយោជន៍*

រាស្ត្ររបស់ព្រះរស់នៅ ហើយរីកចំរើនដោយសារជឿ និងស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់។ ព្រះគម្ពីរមានកំរៃ និងគុណប្រយោជន៏ ជាពិសេស។ បទគម្ពីរ ពុំមានគុណប្រយោជន៍នៅក្នុងផ្លូវអធិធម្មជាតិនោះទេ តែមានគុណប្រយោជន៍ នៅក្នុងវិធីសាស្ត្រសមញ្ញៗដូចជា ការបង្រៀន ការរំលឹកឲ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត (២ធីម៉ូថេ ៣:១៦)។

តាមរយៈវិធីសាស្ត្រទាំងនេះ ព្រះគម្ពីរមានគុណប្រយោជន៍ខ្លាំងណាស់។

## *បទគម្ពីរមានប្រសិទ្ធិភាព*

បទគម្ពីរអះអាងថាមានគុណប្រយោជន៍ ប៉ុន្តែតើ បទគម្ពីរពិតជាសំរេចបានអ្វីទៅ? សូមពិចារណាពាក្យរបស់ហោរាអេសាយម្តងទៀតៈ

> ពីព្រោះដែលភ្លៀងនឹងហិមៈធ្លាក់ចុះមកពីលើមេឃឥតវិលត្រឡប់ទៅលើវិញ គឺមកស្រោចដីធ្វើឱ្យកើតចេញជាពន្លកឡើង ហើយក៏ឱ្យពូជពង្រោះដល់អ្នកដែលព្រោះ នឹងអាហារដល់អ្នកដែលបរិភោគជាយ៉ាងណា នោះពាក្យអញ ដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹងធ្វើសំរេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុងចិត្តអញ ហើយនឹងចំរើនកើនឡើង ក្នុងការអ្វី ដែលអញចាត់ទៅធ្វើនោះ (អេសាយ ៥៥:១០-១១)

លើសពីនេះ អ្នកនិពន្ធកណ្ឌហេព្រើសរសេរថាៈ ពីព្រោះ ឯព្រះបន្ទូលនៃព្រះនោះរស់នៅហើយពូកែផង ក៏មុតជាងដាវណាមានមុខ ២ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹងនិងវិញ្ញាណ ហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត ហើយដែលសំរេចដែរ (ហេព្រើរ ៤:១២)។ នៅពេលអ្នកនិពន្ធកណ្ឌហេព្រើរនិយាយថាព្រះបន្ទូលនៃព្រះ “ពូកែ” ឬ “មានអំណាច” គឺគាត់កំពុងនិយាយថាព្រះបន្ទូលនៃព្រះមានប្រសិទ្ធិភាព ពោលព្រះបន្ទូលនៃព្រះអាចសំរេចបាននូវព្រះរាជបំណងរបស់ព្រះ ហើយ

គាត់និយាយទៀតថា ផលនេះកើតឡើងពីសមត្ថភាពក្នុងការចាក់ទំលុះនៃព្រះបន្ទូលព្រះ។

ចូរពិចារណា អំពី ចំនុចមួយចំនួននៅក្នុងបញ្ជីខាងក្រោម ដែលព្រះបន្ទូលនៃព្រះអះអាងថាអាច ធ្វើបាន៖

១. ព្រះបន្ទូលនៃព្រះផ្ដើមនូវសេចក្ដីជំនឿ៖ «សេចក្ដីជំនឿមកពីលឺ ហើយដែលលឺនោះគឺតាមរយៈព្រះបន្ទូលនៃព្រះគ្រីស្ទ» (រ៉ូម ១០:១៧)។

២. ព្រះបន្ទូលនៃព្រះផ្ដល់ជីវិតថ្មីខាងព្រលឹងវិញ្ញាណ៖ «ត្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ហើយនៅជាប់លាប់» (១ពេត្រុស ១:២៣)។

៣. ព្រះបន្ទូលនៃព្រះជួយឲ្យយើងរីកចំរើនខាងព្រលឹងវិញ្ញាណ៖ «នោះត្រូវសង្វាតរកទឹកដោះសុទ្ធខាងឯព្រលឹងវិញ្ញាណវិញ ដូចជាទារកដែលទើបនឹងកើត ដើម្បីឲ្យអ្នករាល់គ្នាបានចំរើនធំឡើងដរាបដល់បានសង្គ្រោះ» (១ពេត្រុស ២:២)។

៤. ព្រះបន្ទូលនៃព្រះញែកយើងជាបរិសុទ្ធ៖ «សូមញែកគេចេញជាបរិសុទ្ធ ឯសេចក្ដីពិតគឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន ១៧:១៧)។

៥. ព្រះបន្ទូលនៃព្រះពិនិត្យមើលចិត្ត និងកាត់ទោសៈ “ពីព្រោះបន្ទូលនៃព្រះនោះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខពីរ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹងនិងវិញ្ញាណ ហើយសន្លាក់និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលចិត្តគិត ហើយដែលសំរេចដែរ” (ហេព្រើរ ៤:១២)។

៦. ព្រះបន្ទូលនៃព្រះរំដោះឲ្យមានសេរីភាពៈ “បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ហើយសេចក្តី ពិតនឹងប្រោសអ្នករាល់គ្នាឲ្យរួច”(យ៉ូហាន ៨:៣១-៣២)។

៧. ព្រះបន្ទូលនៃព្រះធ្វើឲ្យស្រស់បស់និងកែជាថ្មីៈ “សូមប្រោសទូលបង្គំឲ្យភ្ញាក់ឡើង តាមព្រះបន្ទូលទ្រង់” (ទំនុកដំកើង ១១៩:២៥)។

៨. ព្រះបន្ទូលនៃព្រះកែឡើងវិញ(ប្រោសឲ្យរស់)និងបំភ្លឺៈ “ឯក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់លក្ខណ៍ ក៏កែព្រលឹងឡើងវិញ សេចក្តីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា” (ទំនុកដំកើង ១៩:៧ សូមមើលផងដែរ ខ. ៨-១១)។

នេះគ្រាន់តែជាកិច្ចការខ្លះ ដែលព្រះបន្ទូលនិយាយថាខ្លួនអាចធ្វើបាន។ វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ នៅពេលដែលស្តេចដាវីឌនិយាយថា “មានពរហើយអ្នកណាដែលមិនដើរតាមដំបូន្មានរបស់មនុស្សអាក្រក់.... អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ” (ទំនុកដំកើង

១:១-២)? មនុស្សដែលត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានឹងបាន "ដូចជាដើមឈើដែលដុះនៅក្បែរផ្លូវទឹក ដែលបង្កើតផលតាមរដូវកាល ហើយស្លឹកក៏មិនចេះស្រពោនឡើយ" (ខ. ៣)។ និយាយយ៉ាងសាមញ្ញទៅគឺ ព្រះសព្វព្រះហឫទ័យនឹងចិញ្ចឹម បីបាច់ ថែរក្សា រាស្ត្ររបស់ទ្រង់ឲ្យបានរីកចំរើនធំធាត់ឡើងតាមរយៈព្រះបន្ទូលរបស់ទ្រង់។ បទគម្ពីរគឺជាមធ្យោបាយចំបងដែលព្រះប្រើក្នុងការ ចិញ្ចឹមយើង បីបាច់ថែរក្សាយើង ធ្វើឲ្យយើងរីកចំរើន ហើយសព្វព្រះហឫទ័យនឹងសំរេចនូវ ព្រះរាជបំណងដ៏ល្អរបស់ទ្រង់។

ប្រសិនបើគ្រីស្ទបរិស័ទណាម្នាក់ជឿ និងអនុវត្តតាមសេចក្តីជំនឿមុតមាំទាំងបួននេះនៅក្នុងជីវិត នោះ គ្រីស្ទបរិស័ទម្នាក់នោះនឹងមានសង្ឃឹម ហើយដឹងជាក់ថាព្រះគុណនៃព្រះដែលបានប្រទានមកនៅក្នុងដំណឹងល្អនឹងបំផ្លាស់បំប្រែជីវិតរបស់គាត់តាមរយៈព្រះបន្ទូល។ ប៉ុន្តែ ដាច់ខាត យើងចាំបាច់ត្រូវប្រកាន់យកនូវចរិកលក្ខណៈមួយទៀត។

## យើងត្រូវតែមានការបន្ទាបខ្លួននៅក្នុងចិត្ត

ប្រយោជន៏ឲ្យយើងយល់និងអនុវត្តតាមបទគម្ពីរ ដូចដែលព្រះសព្វព្រះហឫទ័យនោះយើងត្រូវតែ មានចិត្តឆេះឆួល ហើយស្មោះត្រង់ចិត្តនៅក្នុងការ ដាក់ខ្លួនរបស់យើងនៅក្រោមអំណាចនៃបទគម្ពីរ។ ជារឿយៗណាស់ ដោយសារយើងចូលចិត្តគិតខ្ពស់ពីខ្លួនឯង នោះយើងត្រូវល្បួងឲ្យលើកខ្លួនឯងខ្ពស់ជាងព្រះបន្ទូល ហើយធ្វើការវិនិច្ឆ័យនិង វាយតំលៃទៅលើអ្វីដែលព្រះគម្ពីរបង្រៀនវិញ។

ខ្ញុំបានឮរឿងមួយអំពីបុរសម្នាក់ដែលបានទៅ ទីក្រុងប៉ារីសដើម្បីទស្សនា

សារៈមន្ទីរលូវីរេ (Louvre)។ ជាពិសេសគាត់ចង់មើលគំនូរដែលគូរដោយលោក លីនណាដូ ដា វីនឈី (Leonardo Da Vinci) ដែលមានឈ្មោះថា នាងម៉ូណា លីសា (Mona Lisa)។ បន្ទាប់ពីផ្ទៀងផ្ទងមើលគំនូរយ៉ាងផ្ចិតផ្ចង់នៅក្នុងក្រសៃភ្នែករិះគន់អស់មួយស្របក់ក្រោយមក គាត់បាននិយាយថា "ខ្ញុំមិនចូលចិត្តគំនូរនេះទេ"។ អ្នកយាមដែលកំពុងឈរនៅទីនោះបានឆ្លើយតបថា "គំនូរទាំងនេលែងត្រូវបានគេវិនិច្ឆ័យទៀតហើយ។ តែគឺជាអ្នកទស្សនាទេតើដែលត្រូវបានគេវិនិច្ឆ័យវិញ។" ដូចគ្នានឹងព្រះបន្ទូលនៃព្រះដែរ។ ព្រះបន្ទូលនៃព្រះ មិនមែនជាអ្វីដែលត្រូវបានគេវិនិច្ឆ័យនោះទេ។ តែគឺជាអ្នកអានព្រះបន្ទូលទេតើដែលត្រូវបាន ព្រះបន្ទូលវិនិច្ឆ័យវិញ។ សំនួរសួរថាតើអ្នកអានព្រះបន្ទូលមានចិត្តដែល ចុះចូល និងបន្ទាបចុះចំពោះអំណាចដ៏ឥតព្រំដែនរបស់ព្រះតាមរយៈព្រះបន្ទូលដែរឬទេ?

ផ្នែកនៃការចុះចូលចំពោះអំណាច នៃបទគម្ពីរគឺជាការស្ម័គ្រចិត្តដាក់ខ្លួននៅក្រោមការពិនិត្យពិច័យរបស់បទគគម្ពីរ។ យើងគួរតែពិនិត្យមើលចិត្តរបស់យើងឲ្យបានទៀតទាត់។ យើងត្រូវតែពិនិត្យមើលខ្លួនឯងនៅក្រោមព្រះបន្ទូលនៃព្រះ។ ព្រះប្រកាសថា "អញនេះ គឺព្រះយេហូវ៉ា អញស្ទង់ចិត្ត" (យេរេមា ១៧:១០)។ ដើម្បីឆ្លើយតបចំពោះការនេះ សេចក្ដីអធិស្ឋានរបស់យើងគួរតែមានលក្ខណៈដូចគ្នានឹងសេចក្ដីអធិស្ឋានរបស់ដាវីឌ " ឱព្រះអង្គអើយ សូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលបង្គំផង" (ទំនុកដំកើង ១៣៩:២៣)។

កណ្ឌគម្ពីរហេ ព្រើររំលឹកយើងថា តាមរយៈព្រះបន្ទូល ព្រះជ្រាបនូវគំនិតនិងការចង់បានរបស់ចិត្ត (ហេព្រើរ ៤:១២)។ យើងគួរតែ ដាក់ខ្លួនឲ្យបាន

ទៀតទាត់ នៅក្រោមការពិនិត្យពិច័យរបស់បទគម្ពីរ ក្នុងគោលបំណងឲ្យយើងបានផ្លាស់ប្រែដើម្បីជាការឆ្លើយតបចំពោះអ្វីដែល បទគម្ពីរបានបើកសំដែង។ ហើយគោលបំណងនេះមិនគួរគ្រាន់តែជាកាតព្វកិច្ចមួយនោះទេ គឺយើងគួរតែមានអំណរថា នេះគឺជាវិធីសាស្ត្រដែលព្រះប្រើដើម្បីបំពេញសំរេចនូវ ព្រះរាជបំណងក្នុងការប្រោសលោះរបស់ទ្រង់នៅក្នុងជីវិតរបស់យើង។

ជារឿយៗណាស់ នៅពេលព្រះបន្ទូលប្រដៅតម្រង់យើង យើងតែងព្យាយាមគិតថា បទគម្ពីរនេះមិន ត្រូវនឹងយើងទេ ហើយនៅពេលដែលយើងធ្វើបែបនេះ យើងបានរត់គេចចេញពីអ្វីដែលជាព្រះរាជបំណងដ៏ល្អរបស់ព្រះអង្គសំរាប់យើងហើយ។ ពាក្យសំដីរបស់លោក ថមមឹស វ៉តសុន (Thomas Watson) ដែលជាគ្រូគង្វាលពួកពូរីតាន់នៅសតវត្សទី១៧ មានប្រយោជន៍ចំពោះយើង៖

> ចូរទទួលយកគ្រប់ទាំងព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ហាក់បីដូចជាព្រះកំពុងតែនិយាយមកកាន់អ្នកចុះ។ នៅពេលព្រះបន្ទូលបញ្ចេញសំលេងប្រឆាំងនឹងអំពើបាប សូមគិតថា «ព្រះកំពុងមានបន្ទូលប្រឆាំងនឹងអំពើបាបរបស់ខ្ញុំ» នៅពេលព្រះគម្ពីរបង្រៀនអំពីកាតព្វកិច្ចណាមួយ សូមគិតថា «ព្រះកំពុងបង្រៀនខ្ញុំឲ្យធ្វើការនេះ»។ មនុស្សជាច្រើនបានច្រានចោលបទគម្ពីរចេញពីជីវិតរបស់ពួកគេដោយគិតថាបទគម្ពីរនោះគ្រាន់តែជាប់ទាក់ទិន នឹងអស់អ្នកដែល រស់នៅក្នុងសម័យដែលព្រះគម្ពីរត្រូវបានសរសេរឡើងតែប៉ុណ្ណោះ ប៉ុន្តែបើសិនជាអ្នកចង់ទទួលបានគុណប្រយោជន៍ពីព្រះបន្ទូល នោះចូរអនុវត្តតាមព្រះបន្ទូលនៅក្នុងជីវិតរបស់អ្នកចុះ

ថ្នាំពេទ្យនឹងគ្មានប្រសិទ្ធិភាពទេ ប្រសិនបើយើងមិនប្រើវានោះ។[២]

ការបន្ទាបខ្លួនគឺពិតជាចាំបាច់ខ្លាំងណាស់។ ការទន្ទឹងរង់ចាំមើលព្រះបន្ទូលនៃព្រះ សំរេចនូវគោលបំណងរបស់វានៅក្នុងជីវិតរបស់យើង ដោយចិត្តពុះកញ្ជ្រោល ការបន្ទាបខ្លួន និងអំណរដ៏ពោរពេញ។

## វិធីសាស្ត្រកាត់ស្រាយមួយដែលយើងត្រូវការជាចាំបាច់

ជាមួយនិងសេចក្តីជំនឿមុតមាំគ្រឹះ និងចិត្តដែលបានបន្ទាបចុះ ឥឡូវនេះយើងនឹងគិតអំពីរការកាត់ស្រាយបទគម្ពីរ។ ព្រះគម្ពីរសញ្ញាថ្មីបង្ហាញនូវគោលការណ៍សំខាន់ពីរ។

### *ផ្តោតលើព្រះគ្រីស្ទ*

ប្រហែលជាគ្មានបទគម្ពីរណាដែលបង្គាប់បញ្ជា ឲ្យផ្តោតទៅលើព្រះគ្រីស្ទខ្លាំងជាងលូកាជំពូក ២៤ នោះទេ។ ព្រះយេស៊ូវកំពុងមានបន្ទូលជាមួយសិស្សពីរនាក់របស់ទ្រង់ដែលពួកគេមិនបានចំណាំទ្រង់ខណៈពេលដែលពួកគេកំពុងធ្វើដំណើរតាមផ្លូវឆ្ពោះទៅកាន់ភូមិអេម៉ោស។ សិស្សទាំងពីរនាក់នោះបានប្រាប់ព្រះយេស៊ូវអំពីអ្វីដែលបានកើតឡើងកាលពីពីរបី ថ្ងៃមុនថា ព្រះយេស៊ូវដែលពួកគេបានដាក់សេចក្តីសង្ឃឹមលើ ត្រូវបានគេធ្វើគុត ហើយបីថ្ងៃក្រោយមកមានដំណឹងមិនច្បាស់ការថា ទ្រង់បានរស់ពីសុគតឡើងវិញហើយ ។ ព្រះយេស៊ូវឆ្លើយតបដោយមានបន្ទូលថា ‹‹ឱមនុស្សឥតពិចារណា ហើយក្រនឹងជឿអស់ទាំងសេចក្តីដែលពួកហោរាបានទាយទុកមកអើយ តើមិនគួរឲ្យព្រះគ្រីស្ទរង

ទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរីល្អនៃទ្រង់វិញទេឬអី? បន្ទាប់មកលូកាប្រាប់យើងថា "រួចទ្រង់ក៏ស្រាយន័យសេចក្តីដែលតំរូវពីទ្រង់ពីក្នុងគម្ពីរទាំងឡាយឲ្យគេស្តាប់ ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក" (លូកា ២៤:២៥-២៧)។

ក្រោយមកទៀតក្នុងជំពូកដដែល ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សទាំងដប់ពីរដែលប្រជុំគ្នាថា "នេះហើយជាសេចក្តីដែលខ្ញុំបានប្រាប់អ្នករាល់គ្នា កាលនៅ ជាមួយគ្នានៅឡើយ គឺថា ត្រូវតែបានសំរេចគ្រប់ទាំងសេចក្តីដែលបានចែងទុកពីខ្ញុំ ទោះក្នុងក្រឹត្យវិន័យលោកម៉ូសេ ក្នុងទំនាយពួកហោរា ឬក្នុងបទទំនុកដំកើងផង" (ខ. ៤៤)។ លូកាបន្ថែមម្តងទៀតថា "នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេឲ្យបានយល់ក្នុងគម្ពីរ" (ខ. ៤៥)។ អ្វីដែលបានសំដែងយ៉ាងច្បាស់លាស់នៅក្នុងបទគម្ពីរនេះគឺថា ព្រះយេស៊ូវជ្រាបថាព្រះគម្ពីរសញ្ញាចាស់ទាំងមូលបាននិយាយអំពីទ្រង់។

ព្រះយេស៊ូវមានបន្ទូលដូចគ្នានៅក្នុងយ៉ូហានជំពូក៥។ ទ្រង់មានបន្ទូលទៅកាន់ពួកអ្នកដឹកនាំសាសនាក្នុងក្រុងយេរូសាឡឹមថា "អ្នករាល់គ្នាស្ទង់មើលគម្ពីរដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯងដែលធ្វើបន្ទាល់ពីខ្ញុំ" (ខ. ៣៩)។ ម្តងទៀតព្រះយេស៊ូវ ជ្រាបថាព្រះគម្ពីរសញ្ញាចាស់និយាយអំពីទ្រង់ និងចង្អុលទៅកាន់ទ្រង់។

វាច្បាស់លាស់ដែលថាព្រះគម្ពីរសញ្ញាថ្មីនិយាយអំពីព្រះគ្រីស្ទ។ ពួកអ្នកនិពន្ធដែលជាសាវ័កយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការហាមប្រាមមិនឲ្យអស់អ្នកដែលអានអ្វីដែលពួកគេសរសេរ ដកផ្នែកណានៃការសរសេររបស់

ពួកគេចេញពីបុគ្គល និងការងាររបស់ព្រះយេស៊ូវនោះទេ។ ព្រះគម្ពីរទាំងមូល និយាយអំពីព្រះយេស៊ូវនៅក្នុងផ្លូវជាក់លាក់និងស្របតាមព្រះរាជបំណងរបស់ព្រះ។ នៅក្នុងសៀវភៅដ៏មានប្រយោជន៍ដែលមានចំណងជើងថា ការអធិប្បាយដោយផ្ដោតលើព្រះគ្រីស្ទ នោះលោក ប្រៃអាន់ ឆាប់ពិល Bryan Chapell សង្ខេបសេចក្ដីពិតនេះបានយ៉ាងល្អថា: “បទគម្ពីរនិមួយៗទាយអំពីការងាររបស់ព្រះគ្រីស្ទ ត្រៀមរៀបចំសំរាប់ការងាររបស់ព្រះគ្រីស្ទ ងាកក្រោយសំឡឹង ទៅមើលការងាររបស់ព្រះគ្រីស្ទ ហើយ/ឬជាលទ្ធផលនៃការងាររបស់ព្រះគ្រីស្ទ”។[៣] ការនេះមានន័យយ៉ាងច្បាស់ថា បើសិនជាយើងចង់អានព្រះគម្ពីរឲ្យបានត្រឹមត្រូវ នោះយើងត្រូវតែមើលឃើញថាគ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីរទាក់ទងនឹងព្រះគ្រីស្ទ។

ទោះបីជាយ៉ាងណា យើងមិនត្រូវ បង្កើតទំនាក់ទំនងក្លែងក្លាយរវាងបទគម្ពីរ នឹងព្រះយេស៊ូវនៅពេលយើងអានឬបង្រៀនបទគម្ពីរនោះឡើយ។ ផ្ទុយទៅវិញ ព្រះត្រាស់ហៅយើងឲ្យយល់ និងកាត់ស្រាយរបៀបដ៏ជាក់លាក់ដែលបទគម្ពីរចង្អុលទៅកាន់ព្រះគ្រីស្ទ ដោយចងចាំថាព្រះយេស៊ូវបង្រៀនថាគ្រប់ទាំងបទគម្ពីរទាំងអស់ចង្អុលទៅកាន់ទ្រង់។ ប្រយោជន៍ឲ្យការអានព្រះគម្ពីររបស់យើងបានដាក់ដំណឹងល្អនៅកណ្ដាល (ដូចដែលដំណឹងល្អគួរតែត្រូវបានដាក់នៅកណ្ដាលនោះ) នោះការកាត់ស្រាយរបស់យើងត្រូវតែសំឡឹងទៅកាន់ និងផ្ដោតលើព្រះយេស៊ូវ ហើយជាទូទៅ មនុស្សយើងច្រើនតែបរាជ័យក្នុងការសំឡឹងទៅកាន់ ឬផ្ដោតលើព្រះយេស៊ូវនៅពេលអានព្រះគម្ពីរសញ្ញាថ្មីក៏ដូចជានៅពេលអានព្រះគម្ពីរសញ្ញាចាស់ដែរ។

## *ការកាត់ស្រាយខាងព្រលឹងវិញ្ញាណ*

វាមិនគ្រប់គ្រាន់ទេដែលគ្រាន់តែទទួលស្គាល់ថា ការផ្តោតលើព្រះគ្រីស្ទ មានសារៈសំខាន់ក្នុងការកាត់ស្រាយបទគម្ពីរឲ្យបានត្រឹមត្រូវនោះ។ យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធ បំភ្លឺចិត្តគំនិតរបស់យើង នៅពេលយើងអានព្រះគម្ពីរ។ ព្រះគម្ពីរខុសពីសៀវភៅផ្សេងៗទៀត ហើយតំរូវឲ្យយើងអានវានៅក្នុងរបៀបដែលត្រឹមត្រូវតាមលក្ខណៈរបស់វា។

លោកប៉ុលនិយាយអំពីការនេះនៅក្នុងសំបុត្រទីមួយរបស់គាត់ទៅកាន់ពួកជំនុំនៅក្នុងទីក្រុងកូរិនថូស។ បន្ទាប់ពីគាត់បានពិពណ៌នាអំពីព័ន្ធកិច្ចថ្មីៗរបស់គាត់ក្នុងការ “ប្រាប់សេចក្តីបន្ទាល់ពីព្រះដល់(ពួកគេ)” (១កូរិនថូស ២:១) ហើយគាត់បានរំលឹកពួកគេថា ការអធិប្បាយរបស់គាត់ទៅកាន់ពួកគេមិនមែនមកពីប្រាជ្ញារបស់មនុស្សនោះទេ ប៉ុន្តែមកពីអំណាចរបស់ព្រះវិញ (ខ. ៤-៥) គាត់បានសរសេរយ៉ាងដូច្នេះថាៈ

> ប៉ុន្តែ នៅក្នុងចំណោមមនុស្សគ្រប់លក្ខណ៍ នោះយើងខ្ញុំក៏និយាយតាមប្រាជ្ញាដែរ តែមិនមែនតាមប្រាជ្ញា របស់លោកិយនេះ ឬរបស់ពួកចៅហ្វាយនៅលោកិយនេះ ដែលត្រូវសាបសូន្យនោះទេ គឺនិយាយតាមតែប្រាជ្ញានៃព្រះវិញ ជាសេចក្តីអាថ៌កំបាំងដ៏លាក់ទុកដែលព្រះបានគិតគូ តាំងពីមុនអស់ទាំងកល្ប សំរាប់ជាសិរីល្អដល់យើងរាល់គ្នា  គ្មានចៅហ្វាយណាក្នុងលោកិយនេះ បានស្គាល់សេចក្តីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេ ដូចមានសេចក្តីចែង ទុកមកថា

«សេចក្តីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្ត នឹកមិនដែលដល់ គឺសេចក្តីនោះឯង ដែលព្រះបានរៀបចំទុក សំរាប់ ពួកអ្នកដែលស្រឡាញ់ទ្រង់»។ ព្រះទ្រង់បានសំដែង ឱ្យយើងរាល់គ្នា ឃើញសេចក្តីទាំងនោះ ដោយសារព្រះវិញ្ញាណទ្រង់ ដ្បិតព្រះ វិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្តីជ្រាលជ្រៅ នៃព្រះដែរ ដ្បិតបើមិនមែនជាវិញ្ញាណដែលនៅក្នុងខ្លួន មនុស្ស ទេ នោះតើមានអ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន ហើយបើ មិនមែនជាព្រះវិញ្ញាណនៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ឋាន ព្រះបានដែរ ឯយើងរាល់គ្នា យើងមិនបានទទួលវិញ្ញាណទរបស់ លោកិយទេ គឺទទួលព្រះវិញ្ញាណដែលមកពីព្រះវិញ ដើម្បីឱ្យបាន ស្គាល់អស់ទាំងព្រះគុណ ដែលព្រះបានផ្តល់មកយើង ហើយយើង ក៏និយាយពីសេចក្តីទាំងនោះឯង មិនមែនដោយពាក្យសំដី ដែល ប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយពាក្យសំដីដែលព្រះវិញ្ញាណ បង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្តីខាងឯវិញ្ញាណ ដោយសារ សេចក្តីខាងឯវិញ្ញាណផង ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិន ទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ (១កូរិនថូស ២:៦-១៤)

យើងអាចដកស្រង់បួនចំនុចច្បាស់លាស់ចេញពីបទគម្ពីរក្នុង១កូរិនថូស ជំពូក ២ នេះ។ ទីមួយ មានប្រាជ្ញាមួយមកពីព្រះដែលទ្រង់បានបើកសំដែង

ឲ្យមនុស្សបានស្គាល់ (ខ. ១០, ១២)។ ទីពីរ ប្រាជ្ញានោះត្រូវបានបើកសំដែងតាមរយៈព្រះវិញ្ញាណ (ខ. ១០)។ ទីបី ដោយសារព្រះវិញ្ញាណទ្រង់ជាអ្នកបើកសំដែងប្រាជ្ញានោះ នោះ តម្រូវឲ្យព្រះវិញ្ញាណធ្វើជាអ្នកកាត់ស្រាយប្រាជ្ញានោះ (ខ. ១៣)។ ទីបួន ព្រះបានប្រទានព្រះវិញ្ញាណដល់ពួកអ្នកជឿ "ដើម្បីអោយយើងបានស្គាល់អស់ទាំងព្រះគុណ ដែលព្រះបានផ្តល់មកយើង" (ខ. ១២)។ ព្រះបានប្រទានព្រះវិញ្ញាណដល់ទាំងអស់អ្នកដែលបង្រៀន (ខ. ១២) និងដល់អស់អ្នកដែលស្តាប់ (ខ. ១៣-១៤)។ យើងមិនអាចយល់ព្រះបន្ទូលនៃព្រះបានយ៉ាងត្រឹមត្រូវ ដោយគ្មានជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធនោះឡើយ។ គឺជាព្រះវិញ្ញាណបរិសុទ្ធដែលប្រទានឲ្យមនុស្សមានសមត្ថភាពដឹងថា បទគម្ពីរសុទ្ធតែពិត ហើយឲ្យយល់សេចក្តីពិតនៃបទគម្ពីរនោះ។

## *របៀបពីរយ៉ាងក្នុងការអានព្រះគម្ពីរ*

ឥឡូវយើងនឹងសិក្សាអំពីការអានព្រះគម្ពីរ។ នៅទីនេះយើងមិនមែនកំពុងតែនិយាយអំពីជំនាញក្នុងការអានបទគម្ពីរជាសាធារណៈនោះទេ ប៉ុន្តែនិយាយអំពីការអាន ការកាត់ស្រាយ និងការអនុវត្តតាមព្រះគម្ពីរផ្ទាល់ខ្លួនវិញ ទោះជាការសិក្សាផ្ទាល់ខ្លួន ឬកំពុងវាយតំលៃលើការកាត់ស្រាយព្រះបន្ទូលរបស់គ្រូឯទៀត។ តើ "ការកាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ" មានលក្ខណៈដូចម្តេច (២ធីម៉ូថេ ២:១៥)?

ព្រះគម្ពីរគួរឲ្យចាប់អារម្មណ៍មិនចេះចប់នោះទេ ពីព្រោះវាគឺជារឿងរបស់ព្រះ ហើយព្រះជាម្ចាស់ផ្ទាល់គួរឲ្យចាប់អារម្មណ៍មិនចេះចប់ដែរ។ ព្រះគម្ពីរគឺជា

ប្រភពទឹកដែលតែងតែហូរ។ កាលណាអ្នកកាន់តែអានវា អ្នកកាន់តែមើលឃើញថាសេចក្តីពិត និងសោភ័ណ្ឌភាពរបស់វាគ្មានដែនកំណត់នោះឡើយ។

មានវិធីសាស្ត្រនៃការអានព្រះគម្ពីរជាច្រើន ហើយដោយសារតែព្រះគម្ពីរមិនចេះរីងស្ងួត នោះមានវិធីសាស្ត្រជោគជ័យៗជាច្រើន។ វិធីសាស្ត្រអានព្រះគម្ពីរសំខាន់ពីរយ៉ាងដែលមានប្រយោជន៍ក្នុងការស្រាយបង្ហាញមរតករបស់ព្រះគម្ពីរដែលជាដំណឹងល្អ។

*ការអានព្រះគម្ពីរជានិទានកថាភាគ (ឬប្រវត្តិសាស្ត្រ)*

ព្រះគម្ពីរគឺជាដំណើររឿង ប្រវត្តិសាស្ត្រ ដែលមានអំណះអំណាងច្រើន ហើយចេតនាផ្សាភ្ជាប់ជាមួយនិង តួអង្គ ព្រឹត្តិការណ៍ និងទីតាំងប្រវត្តិសាស្ត្រដែលមនុស្សយើងស្គាល់ (ឧទាហរណ៍ៈ លូកា ៣ៈ១-៣)។ គ្មានអ្វីគួរឲ្យសង្ស័យឡើយ ព្រះគម្ពីរពិតជាបានកត់ត្រា និងបង្ហាញនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រគួរឲ្យទុកចិត្តបាន។ ការអានព្រះគម្ពីរដោយឈរលើទស្សនៈវិស័យប្រវត្តិសាស្ត្រមានន័យថាយើងអាននិទានកថាតាមព្រះគម្ពីរជា "ភាគបន្តបន្ទាប់"។ ព្រះគម្ពីរចងក្រងសំណេរជាច្រើនដែលសរសេរដោយអ្នកនិពន្ធផ្សេងៗ គ្នាជាច្រើននាក់ ហើយដំបូងចំនុចនេះ អាចជារឿងមួយពិបាកសំរាប់ពួកអ្នកអាន ដែលកំពុងតែព្យាយាមយល់គ្រប់ផ្នែកទាំងអស់នៃប្រវត្តិសាស្ត្រនេះ។

ប៉ុន្តែព្រះគម្ពីរមិនត្រឹមតែជានិទានកថាដែលកត់ត្រាទុកនូវប្រវត្តិសាស្ត្ររបស់មនុស្សជាតិប៉ុណ្ណោះនោះទេ។ មានរឿងមួយ ធំជាងដែលស្ថិតនៅពីក្រោយនិទានកថាមួយនេះ។ ការបើកសំដែងអំពីព្រះរាជបំណង និងផែនការ

របស់ព្រះ គឺជាខ្លឹមសារពិតនៃនិទានកថាតាមព្រះគម្ពីរ។ ព្រះគម្ពីរគឺជារឿងរបស់ព្រះ ហើយ ដំណើររឿងរបស់វាគឺជាដំណឹងល្អស្តីអំពី៖ ផែនការរបស់ព្រះក្នុងការជ្រោសលោះមនុស្សមួយចំនួនទុកជារាស្ត្ររបស់ទ្រង់ ហើយស្តារ ឡើងវិញនូវស្នាព្រះហស្តរបស់ទ្រង់ដែលបានធ្លាក់ចុះទៅក្នុងអំពើបាបតាមរយៈអង្គព្រះគ្រីស្ទ។

## *ការអានព្រះគម្ពីរជាសង្ខេបកថាកើតចេញពីទស្សនៈវិស័យរបស់ព្រះ (ឬទេវសាស្ត្រ)*

ព្រះគម្ពីរមិនគ្រាន់តែកត់ត្រាទុកនូវប្រវត្តិសាស្ត្រនោះទេ វាក៏កាត់ស្រាយប្រវត្តិសាស្ត្រផងដែរ។ បទគម្ពីរបានប្រទានមកដល់យើងក្នុងទំរង់ផ្សេងៗដូចជា សេចក្តីប្រកាស ក្រឹត្យវិន័យ សេចក្តីសន្យា សុភាសិត ការត្រាស់ហៅ...។ល។ ប៉ុន្តែគ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីរសុទ្ធតែកើតចេញពីទស្សនៈវិស័យរបស់ព្រះ។ ការអានព្រះគម្ពីរដោយឈរលើទស្សនៈវិស័យខាងផ្នែកទេវសាស្ត្រដូចគ្នានឹងការអានព្រះគម្ពីរ“ចោះៗ”ស្របទៅតាមផ្ទៃរឿង។ វិធីសាស្ត្រនៃការអានព្រះគម្ពីរដោយឈរលើទស្សនៈវិស័យនេះមានន័យថា យើងបែងចែកសេចក្តីបង្រៀននៃព្រះគម្ពីរជាក្រុម ស្របទៅតាមផ្ទៃរឿងដើម្បី ជួយឲ្យយើងយល់ច្បាស់អំពីអ្វីដែលព្រះគម្ពីរទាំងមូលកំពុងបង្រៀន។ ការអានរបៀបនេះចាំបាច់ឲ្យយើងផ្តោតចំណាប់អារម្មណ៍បន្ថែមទៅលើលក្ខណៈនៃកណ្ឌគម្ពីរ និងបទគម្ពីរនិមួយៗ ប៉ុន្តែវាជាភាពវៃឆ្លាតក្នុងការចងចាំថា អត្ថន័យនៃបទគម្ពីរនិមួយៗមានទំនាក់ទំនងគ្នានឹងអត្ថន័យនៃបទគម្ពីរឯទៀត ពីព្រោះបទគម្ពីរ

ទាំងអស់សុទ្ធតែជាផ្នែកនៃព្រះបន្ទូលរួមមួយដែលមកពីព្រះ។

## *ព្រះរាជសារតែមួយនៃព្រះគម្ពីរ*

ព្រះរាជសារនៃព្រះគម្ពីរ ដូចគ្នា ទោះបីជាយើងអានព្រះគម្ពីរជានិទានកថាភាគ ឬជាការប្រមូលផ្តុំនូវទស្សនៈវិស័យដែលកើតចេញពីព្រះក៏ដោយ។ ប្រសិនបើយើងអានព្រះគម្ពីរជានិទានកថាភាគ នោះដំណើររឿងរបស់វានឹងចាប់ផ្តើមពីកំណាកំណើតពីពិភពលោក ការធ្លាក់ចុះទៅក្នុងអំពើបាប ការប្រោសលោះ និងការស្តារឡើងវិញ។ ប្រសិនបើយើងអានព្រះគម្ពីរជាការប្រមូលផ្តុំនូវទស្សនៈវិស័យខាងផ្នែក ទេវសាស្ត្រ នោះផ្ទៃរឿងដែលលេចឡើងគឺព្រះ អំពើបាប ព្រះគ្រីស្ទ និងសេចក្តីជំនឿ។ របៀបអានទាំងពីរសុទ្ធតែមានព្រះរាជសារស្តីអំពីការសម្រេចដោយជោគជ័យនូវព្រះរាជបំណងក្នុងការប្រោសលោះដ៏អស់កល្បជានិច្ចរបស់ព្រះ។ របៀបអានព្រះគម្ពីរទាំងពីរនេះមិនប្រឆាំងគ្នាទេ។ ផ្ទុយទៅវិញ យើងចាំបាច់ត្រូវការប្រើរបៀបទាំងពីរដើម្បីអោយយើងអាចយល់ និង «លឺ» ដំណឹងល្អតាមព្រះគម្ពីរបានយ៉ាងពេញលេញ ហើយនឹងជួយឲ្យយើងមើលឃើញអំពីរបៀបដែលគ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីររួបរួមគ្នា និងចង្អុលបង្ហាញឲ្យយើងមើលឃើញព្រះយេស៊ូវ។

## *ការពន្យល់បង្ហាញនូវអត្ថន័យនៃបទគម្ពីរមួយ ដកស្រង់ពីម៉ាថាយ ជំពូក ១២*

យើងអាចពន្យល់បង្ហាញយ៉ាងសង្ខេបអំពីរបៀបដែលវិធីសាស្ត្រនៃការ

អានព្រះគម្ពីរទាំងពីរនេះជួយ បំពេញ គ្នាទៅវិញទៅមក ដោយប្រើប្រាស់របៀបទាំងពីរនៅក្នុងការអានបទគម្ពីរមួយៈ

> នៅគ្រានោះព្រះយេស៊ូវទ្រង់យាងកាត់ស្រែ នៅថ្ងៃឈប់សំរាក ឯពួកសិស្សទ្រង់គេឃ្លាន ហើយគេចាប់បូតគួរ ស្រូវបរិភោគទៅ ពួកផារិស៊ីក៏ឃើញ ហើយគេទូលទ្រង់ថា មើលន៏ សិស្សលោកធ្វើអំពើដែលគ្មានច្បាប់ធ្វើនៅថ្ងៃឈប់សំរាកហើយ។ តែទ្រង់មានបន្ទូលតបថា តើអ្នករាល់គ្នាមិនដែលមើលរឿង ពីការដែលហ្លួងដាវីឌទ្រង់ធ្វើក្នុងកាលដែលទ្រង់ និង ពួកអ្នកនៅជាមួយបានឃ្លានទេឬអី? គឺដែលទ្រង់បានយាង ចូលទៅក្នុងដំណាក់ព្រះ ហើយបានសោយនំប៉័ងតាំងទុក ដែលគ្មានច្បាប់អោយទ្រង់សោយ ឬពួកដែលនៅជាមួយ នឹងទ្រង់ផង ជារបស់ទុកសំរាប់តែពួកសង្ឃមប៉ុណ្ណោះ ឬអ្នករាល់គ្នាមិនបានមើលក្នុងក្រិត្យវិន័យទេឬអីថា នៅថ្ងៃឈប់សំរាកនោះពួកសង្ឃ នៅក្នុងព្រះវិហារ ក៏ប្រព្រឹត្តរំលងច្បាប់ នៃថ្ងៃឈប់សំរាកឥតមានទោសវិញ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា នៅទីនេះមាន១អង្គ ដែលវិសេសជាងព្រះវិហារទៅទៀត បើអ្នករាល់គ្នាបានយល់ន័យសេចក្តីដែលថា «អញចង់បានសេចក្តីមេត្តាករុណា មិនមែនយញ្ញបូជាទេ» នោះ អ្នករាល់គ្នាមិនបានបន្ទោស ដល់ពួកអ្នកដែលគ្មានទោសឡើយ ដ្បិតកូនមនុស្សជាម្ចាស់លើថ្ងៃឈប់សំរាកដែរ។ (ម៉ាថាយ ១២:១-៨)

ការអានបទគម្ពីរនេះតាម**វិធីសាស្រ្តនៃការអានព្រះគម្ពីរជានិទានកថាភាគ**

ផ្តោតទៅលើរបៀបដែលរឿងក្នុង១សាំយ៉ូអែលជំពូក ២១ អំពីស្តេចដាវីឌ ហើយ និងក្រុមរបស់ ទ្រង់ឆ្លុះបញ្ចាំងអំពីព្រះគ្រីស្ទ។ តើព្រះយេស៊ូវកំពុងតែផ្សាភ្ជាប់ នូវទំនាក់ទំនងអ្វីរវាងស្ថានភាពរបស់ទ្រង់ និងរឿងរបស់ស្តេចដាវីឌ? តើ រឿងនៅក្នុងជីវិតរបស់ស្តេចដាវីឌនេះបានកើតឡើងក្នុងថ្ងៃសាប្ប័ទឬ? យើង មិនដឹងថាថ្ងៃណាដែលដាវីឌបានចូលទៅក្នុងដំណាក់របស់ព្រះនោះទេ។ បើ សិនថ្ងៃសាប្ប័ទគឺជាហេតុផលដែលព្រះយេស៊ូវបានលើករឿងនេះឡើង នោះ ទ្រង់ច្បាស់ជាមានព្រះបន្ទូលថា ព្រឹត្តិការណ៍នៅក្នុងជីវិតរបស់ស្តេចដាវីឌ មួយ នេះបានកើតឡើងនៅថ្ងៃសាប្ប័ទ ប៉ុន្តែទ្រង់មិនបានមានបន្ទូលបែបនោះទេ។

ដូច្នេះ តើអ្វីគឺជាទំនាក់ទំនងទៅ? តើព្រះយេស៊ូវកំពុងតែមានព្រះបន្ទូល ថា “បើសិនជាការប្រព្រឹត្តរំលងក្រឹត្យវិន័យម្តងមិនអី នោះការប្រព្រឹត្តរំលង ក្រឹត្យវិន័យម្តងទៀតក៏មិនអីដែរ មែនទេ?” នោះពិតជាមិនមែនជាទំនាក់ទំនង ទេ ពីព្រោះព្រះយេស៊ូវបានបង្រៀនមុននេះបន្តិចអំពីការលើកស្ទួយក្រឹត្យវិន័យ (ប្រៀបធៀបៈ ម៉ាថាយ ៥:១៧)។

ព្រះយេស៊ូវបង្រៀនថា ពួកគេមិនបានប្រព្រឹត្តរំលងក្រឹត្យវិន័យនោះទេ គឺពួកគេ “គ្មានទោស” នោះទេ។ ទំនាក់ទំនងរវាង១សាំយ៉ូអែល ជំពូក ២១ និងស្ថានភាពរបស់ព្រះគ្រីស្ទមិនមែនជាពេលដែលរឿងរបស់ដាវីឌបានកើត ឡើង ឬអ្វីដែលបានកើតឡើងក្នុងរឿងនោះទេ។ ទំនាក់ទំនងនោះគឺថាតើអ្នក ណានៅក្នុងរឿងនោះ ហើយការកត់សំគាល់នូវលំហូរនៃនិទានកថាក្នុងបទ គម្ពីរនេះនឹងជួយឲ្យយើងមើលឃើញសេចក្តីពិតនោះ។ មានតែពួកសង្ឃទេ ដែលអាចបរិភោគនំប៉័ងតាំងទុក លើកលែងតែ ឬជាក់ស្តែងណាស់ មនុស្ស

ម្នាក់ដែលមានអំណាចធំជាងពួកសង្ឃបានមកដល់ គឺជាម្នាក់ដែលត្រូវបានចាក់ប្រេងតាំងឲ្យឡើងធ្វើជាស្តេច ហើយមានអំណាចលើក្រឹត្យវិន័យ។

តាមរយៈការលើកឡើងនូវរឿងក្នុងព្រះគម្ពីរសញ្ញាចាស់នេះ តើព្រះយេស៊ូវកំពុងតែមានព្រះបន្ទូលប្រាប់ពួកផារ៉ាស៊ីថា ម្នាក់ដែលធំ ឬធំជាងស្តេចដាវីឌកំពុងមានវត្តមានចំពោះមុខពួកគេ ហើយថាពួកផារ៉ាស៊ីគួរតែបានទទួលស្គាល់ព្រះអង្គដូចជាអ័ហ៊ីម៉ាលេកបានទទួលស្គាល់ស្តេចដាវីឌ ក្នុង១សាំយ៉ូអែល ជំពូក ២១ ជាអ្នកដែលមានអំណាចធំជាងមែនទេ? សេចក្តីពិតនោះត្រូវបានបង្កប់នៅក្នុង ខ ៣ និងខ ៤ហើយត្រូវបានបញ្ជាក់ច្បាស់ និងចំៗនៅក្នុងខបន្ទាប់នៅពេលព្រះយេស៊ូវប្រកាសអំពីឧត្តមភាពរបស់ទ្រង់លើទាំងសង្ឃ និងព្រះវិហារ។ ទាំងអស់ពឹងផ្អែកលើអត្តសញ្ញាណរបស់ព្រះយេស៊ូវ ហើយដំណើរនិទានកថាបន្តពីស្តេចដាវីឌ មកទៀតដែលចង្អុលបង្ហាញឲ្យយើងស្គាល់អំពីអត្តសញ្ញាណរបស់ព្រះយេស៊ូវ។ វិធីសាស្ត្រក្នុង**ការអានព្រះគម្ពីរជានិទានកថាភាគ** រំលេចច្បាស់ថាព្រះយេស៊ូវគឺជាខ្សែស្រឡាយរបសស្តេចដាវីឌ ហើយកំណត់ត្រារបស់លោកម៉ាថាយអំពីព្រះបន្ទូលរបស់ព្រះយេស៊ូវបង្ហាញអំពីភាពជាស្តេច និងអំណាចរបស់ព្រះគ្រីស្ទ។

ឥឡូវនេះយើងនឹងអានបទគម្ពីរដូចគ្នានេះដោយប្រើវិធីសាស្ត្រខាងផ្នែកទេវសាស្ត្រ និងផ្ទៃរឿង។ តើអ្វីទៅគឺជាលទ្ធផលនៃ**ការអានព្រះគម្ពីរដោយប្រមូលផ្តុំ**នូវទស្សនៈវិស័យខាងផ្នែកទេវសាស្ត្រស្របទៅតាមផ្ទៃរឿង? វិធីសាស្ត្រនេះនាំយើងឲ្យផ្តោតទៅលើ ផ្ទៃរឿងស្តីអំពីវត្តមានរបស់ព្រះ ដែលជាផ្ទៃរឿងដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ព្រះវិហារមានសារៈសំខាន់ណាស់

ហើយបើយើងប្រើនូវវិធីសាស្ត្រមួយនេះ យើងនឹងឃើញថា ព្រះយេស៊ូវបានមានព្រះបន្ទូលសំដៅទៅលើអង្គទ្រង់ ថាជា «១អង្គដែលវិសេសជាងព្រះវិហារទៅទៀត» ឥឡូវនេះបានត្រឡប់ជាចំនុចមួយសំខាន់ ព្រោះវាបង្រៀនថា ព្រះគ្រីស្ទគឺជាវត្ថុមានថ្មីរបស់ព្រះនៅក្នុងលោកិយ ជាពិសេសនៅក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់។ តាមរយៈផ្ទៃរឿងនេះ អធិបតីភាពរបស់ព្រះយេស៊ូវលើទាំងថ្ងៃសាប្ប័ទនិងអស់អ្នកដែលរក្សានូវថ្ងៃសាប្ប័ទ ពិតជាមានន័យសមហេតុសមផលបំផុត។

នៅចុងបញ្ចប់ ការកាត់ស្រាយទាំងពីរនាំយើងទៅកាន់ព្រះគ្រីស្ទ។ គ្រប់យ៉ាងចង្អុលទៅកាន់ព្រះគ្រីស្ទហើយទទូចឲ្យយើងមកឯទ្រង់ដូចដែលព្រះគ្រីស្ទអង្គទ្រង់ទទូចដែរៈ «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានឈប់សំរាក ចូរទទួលនឹងខ្ញុំ ហើយរៀននឹងខ្ញុំចុះ ត្បិតខ្ញុំស្លូតហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង» (ម៉ាថាយ ១១:២៨-២៩)។ ក្នុងរបៀបនេះ វិធីសាស្ត្រនៃការអានព្រះគម្ពីរទាំងពីរ រួមចំណែកក្នុងការធ្វើឲ្យមនុស្សស្តាប់លឺនូវព្រះរាជសារនៃដំណឹងល្អ។

ពីបទគម្ពីរមួយទៅបទគម្ពីរមួយទៀត យ៉ាងហោចណាស់លទ្ធផលនៃការអានព្រះគម្ពីរ គឺដើម្បីឲ្យយើងបាន ស្តាប់លឺដំណឹងល្អម្តងហើយម្តងទៀត។ ហើយយ៉ាងហោចណាស់ ក្នុងបទគម្ពីរនិមួយៗយើងអាចផ្តោតទៅលើដំណឹងល្អដល់ទៅពីរដង ម្តងតាមរយៈវិធីសាស្ត្រនៃការអានព្រះគម្ពីរជានិទានកថាភាគ និងម្តងទៀតជាផ្ទៃរឿង ហើយវិធីសាស្ត្រនិមួយៗរួមផ្សំគ្នាដើម្បីធ្វើឲ្យសេចក្តីពិតកាន់តែមានភាពរស់រវើកឡើង ហើយពង្រឹងអំណាចនៃដំណឹងល្អ

របស់ព្រះយេស៊ូវគ្រីស្ទ។

## *ការសន្និដ្ឋានៈ ដំណឹងល្អគឺជាបុព្វហេតុ និងលទ្ធផលនៃបទគម្ពីរ*

យើងធ្វើការសន្និដ្ឋានតាមរបៀបដូចគ្នានឹងនៅពេលដែលយើងបានចាប់ផ្តើម។ ការបើកសំដែងរបស់ព្រះដែលត្រូវបានប្រទានមកតាមរយៈព្រះគម្ពីរ គឺសុទ្ធតែនិយាយអំពីផែនការប្រោសលោះដ៏ធំមហិមា និងអស់កល្បជានិច្ចរបស់ព្រះ។ វាគឺជាអ្វីដែលបណ្តាលឲ្យព្រះគម្ពីរត្រូវបានសរសេរឡើង ហើយព្រះគម្ពីរគឺជាឧបករណ៍ដែលព្រះប្រើក្នុងគោលដៅ បំពេញសំរេចនូវផែនការប្រោសលោះដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ដំណឹងល្អគឺជាផ្ទៃរឿងដែលមានព្រះចេស្តាតែមួយរបស់ព្រះគម្ពីរៈ តាមរយៈជីវិតដែលគ្មានបាបសោះ ការសុគតជំនួស ការរស់ពីសុគតឡើងវិញ ព័ន្ធកិច្ចនាពេលបច្ចុប្បន្ន និងការយាងត្រឡប់មកវិញដោយជ័យជំនះរបស់ព្រះគ្រីស្ទ គឺនៅពេលដែលគ្រប់ទាំងអស់ «ទាំងរបស់នៅស្ថានសួគ៌ និងរបស់នៅផែនដី» ត្រូវបានបំព្រួមនៅក្នុងទ្រង់ (អេភេសូរ ១:១០)។ ព្រះនឹងបំពេញសំរេចព្រះរាជបំណងដ៏ល្អឥតខ្ចោះរបស់ទ្រង់ សំរាប់មនុស្សជាតិ និងស្នាព្រះហស្តទាំងអស់។

សេចក្តីទាំងប៉ុន្មានខាងលើនេះគួរតែបានបង្រៀនយើងអំពីរបៀបអាន និងគ្រប់គ្រងលើ «ការកាត់ស្រាយ» ព្រះបន្ទូលនៃព្រះទាំងអស់របស់យើង ទោះទាំងក្នុងការអានផ្ទាល់ខ្លួន ការកាត់ស្រាយ និងការអនុវត្តតាមព្រះបន្ទូលនោះ និងក្នុងការប្រកាសព្រះបន្ទូលដោយអំណររបស់យើង សំរាប់ថ្វាយជាសិរីល្អដល់ព្រះ

ហើយនិងសេចក្ដីល្អរបស់អស់អ្នកដែលបានប្រោសលោះហើយ។

## សំរាប់ការអានបន្ថែម

Clowney, Edmund P. The Unfolding Mystery: Discovering Christ in the Old Testament. Phillipsburg, NJ: P&R, 1988.

Goldsworthy, Graeme. The Goldsworthy Trilogy. Exeter: Paternoster, 2000.

Roberts, Vaughan. God's Big Picture: Tracing the Storyline of the Bible. Downers Grove, IL: InterVarsity, 2002. (បានបកប្រែជាភាសាខ្មែរ វិសាលភាពនៃព្រះជាម្ចាស់ : ប្រភពប្រាជ្ញា)

## កំណត់

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

២. From his sermon entitled "How We May Read the Scriptures with Most Spiritual Profit," as quoted in Donald Whitney, Spiritual Disciplines for the Christian Life (Colorado Springs: NavPress, 1991), 53.

៣. Bryan Chapell, Christ-Centered Preaching: Redeeming the Expository Sermon (Grand Rapids, MI: Baker, 1994), 275.